**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**រាជបណ្ឌិត្យសភាកម្ពុជា**

Royal Academy of Cambodia
Académie Royale du Cambodge

**គណៈកម្មាធិការលទ្ធកម្ម (គ.លក-PC)**

លេខៈ ០៣៣ /២១ ស.ជ.ណ

ថ្ងៃ ............ ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ការបោះពុម្ពព្រឹត្តិបត្រលេខ១២ សទ្ធានុក្រមភាសាវិទ្យា សទ្ធានុក្រមកសិកម្ម និងក្បាលលិខិតរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២១

រាជបណ្ឌិត្យសភាកម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រាជបណ្ឌិត្យសភាកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ សម្រាប់ការបោះពុម្ពព្រឹត្តិបត្រលេខ១២ សទ្ធានុក្រមភាសាវិទ្យា សទ្ធានុក្រមកសិកម្ម និងក្បាលលិខិតរបស់រាជបណ្ឌិត្យសភាកម្ពុជាឆ្នាំ២០២១។

រាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានអាសយដ្ឋាននៅ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ (អគារF ជាន់ទី២) ចាប់ពីថ្ងៃទី ..០១..... ខែ.......... ឆ្នាំ២០២១ រៀងរាល់ម៉ោងធ្វើការ (ទូរសព្ទទាក់ទងលេខៈ ០១៧ ៦៩៩ ៩៨៧)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង .......:០០..... ថ្ងៃទី ៣០...... ខែ.......... ឆ្នាំ២០២១។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅ អង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង.......:០០. ថ្ងៃទី ..........ខែ.......... ឆ្នាំ២០២១ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយ អង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**និងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

**បណ្ឌិតសភាចារ្យ សុខ ទូច**

**ចម្លងជូន៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ-
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ



អាសយដ្ឋាន ៖ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ - ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ កម្ពុជា
Tel/Fax: (855) 23 890 180, Website: www.rac.gov.kh, E-mail: info@rac.gov.kh, P.O.Box 531 Phnom Penh, Cambodia